**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jul-2015, 15:41
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់ [សាធារណៈ: គោសលុប]

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើទីប្រាំរបស់ នួន ជា សុំឲ្យពិចារណា និងទទួលយកភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១ [គោសលុប]**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA- MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Anta GUISSÉ
លោក Arthur VERCKEN

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញា សូមឆ្លើយតបទៅនឹងសំណើទីប្រាំរបស់ នួន ជា សុំឱ្យពិចារណាលើភ័ស្តុតាងបន្ថែម ("សំណើសុំភ័ស្តុតាងបន្ថែមទីប្រាំ")[1]។ នួន ជា ស្វែងរកការអនុញ្ញាតឱ្យទទួលយកឯកសារបន្ថែម ចំនួនប្រាំមួយ និងកោះហៅសាក្សីបណ្តឹងសាទុក្ខបន្ថែមចំនួនប្រាំនាក់។ សហព្រះរាជអាជ្ញា សន្និដ្ឋានថា នួន ជា ខកខានមិនបានមិនបានបង្ហាញថា សាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំងប្រាំ ឬឯកសារបន្ថែមណាមួយអាចជាកត្តាកំណត់ក្នុងសាលក្រម ស្របតាមអត្ថន័យនៃវិធាន១០៨(៧) ឡើយ និងមិនមានប្រយោជន៍សម្រាប់យុត្តិធម៌ដែលតម្រូវឱ្យទទួលយកតាមវិធាន១០៤(១)នៃវិធានផ្ទៃក្នុងឡើយ។ អង្គជំនុំជម្រះគួរច្រានចោលពាក្យសុំឱ្យកោះហៅសាក្សីបណ្តឹងសាទុក្ខបន្ថែម និងពាក្យសុំឱ្យទទួលយកភ័ស្តុតាងបន្ថែមនេះ លើកលែងតែឯកសារពីរពាក់ព័ន្ធនឹងសាក្សី ដែលបានស្តាប់សវនាការរួចហើយដោយអង្គជំនុំជម្រះនេះ គឺសាក្សី SCW-5[2] ដោយហេតុថា ឯកសារទាំងនោះ អាចជួយដល់អង្គជំនុំជម្រះនៅក្នុងការវាយតម្លៃលើសក្ខីកម្មដែលបានស្តាប់រួច។

## II. ច្បាប់ជាធរមាន

2. នួន ជា ស្វែងរកការអនុញ្ញាតឱ្យទទួលយកភ័ស្តុតាងថ្មីនេះអនុលោមតាមវិធាន ១០៨(៧) និង/ឬ វិធាន ១០៤(១)។ ដើម្បីអនុវត្តវិធាន ១០៨(៧) អជតក បានបង្កើតឱ្យមានតេស្តសាកល្បងមុខបី ដែលអនុលោមតាមតេស្តនេះ ភាគីដាក់ពាក្យសុំត្រូវកំណត់ឱ្យបានថា ភ័ស្តុតាងថ្មីដែលខ្លួនស្នើឡើង សម្រាប់ឱ្យទទួលយកក្នុងបណ្តឹងសាទុក្ខនោះ (១) មិនអាចរកបាននៅពេលសវនាការ បើទោះបីជាបានខំប្រឹងប្រែងព្យាយាមយ៉ាងត្រឹមត្រូវក៏ដោយ; (២) អាចជាកត្តាកំណត់ដើម្បីឈានដល់ការសម្រេចនៅក្រោមបណ្តឹងសាទុក្ខ និង (៣) ពាក់ព័ន្ធទៅនឹងការរកឃើញជាក់លាក់ណាមួយនៃអង្គហេតុដោយអង្គជំនុំជម្រះ[3]។ ពាក់ព័ន្ធទៅនឹងមុខព្រួញទីបីនេះ សំខាន់ត្រូវកត់សំគាល់ថា បើ

---

[1] **F2/7** សំណើទីប្រាំរបស់ នួន ជា សុំឱ្យពិចារណា និងទទួលយកភ័ស្តុតាង ពាក់ព័ន្ធបណ្តឹងសាទុក្ខប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១, ២៥ មិថុនា ២០១៥ ("សំណើសុំភ័ស្តុតាងបន្ថែមទីប្រាំ")។

[2] ទោះបីជាសាក្សី SCW-5 បានផ្តល់សក្ខីកម្មរួចហើយៗអាចនិយាយចំឈ្មោះក៏ដោយ និងដោយសារមានការប្រុងប្រយ័ត្នជាច្រើន ព្រមទាំងដើម្បីឆ្លុះបញ្ចាំងសេចក្តីយោងដែលបានប្រើនៅក្នុងសំណើសុំបន្ថែមភ័ស្តុតាងទីប្រាំ សហព្រះរាជអាជ្ញាសូមបន្តប្រើរហស្សនាមរបស់សាក្សី SCW-5 នៅក្នុងការដាក់ឯកសារនេះ។

[3] **F2/5** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, ២៩ ឧសភា ២០១៥, ត្រង់កថាខណ្ឌ ១៦។

អនុលោមតាមពាក្យពេចន៍ធម្មតារបស់វា ពាក្យថាពាក់ព័ន្ធ ត្រូវតែពាក់ព័ន្ធទៅនឹងការរកឃើញជាក់លាក់ណាមួយនៃអង្គហេតុដោយអង្គជំនុំជម្រះ មិនមែនតាមអំណះអំណាងរបស់ភាគីណាមួយលើបណ្តឹងសាទុក្ខទេ។ អជតក បានសង្កត់ធ្ងន់ថា ការបង្ហាញថាភស្តុតាងមិនអាចរកបាននៅពេលសវនាការ បើទោះបីជាបានខំប្រឹងប្រែងព្យាយាមយ៉ាងត្រឹមត្រូវក៏ដោយ "គឺជាចំណុចសំខាន់ខានមិនបានដើម្បីបញ្ចៀសយុទ្ធសាស្ត្រវិវាទកម្មកុំឱ្យមានការរាំងស្ទះ និងគ្មានប្រសិទ្ធភាព"[4]។

3. វិធាននេះបង្កើតបទដ្ឋានកម្រិតខ្ពស់មួយ សម្រាប់ការទទួលយកភស្តុតាងថ្មីសម្រាប់បណ្តឹងសាទុក្ខ។ ក្រៅអំពីគ្រាន់តែមានការពាក់ព័ន្ធ ភស្តុតាងត្រូវតែមានទម្ងន់ និងសារៈសំខាន់ដែលអាចប្រើជា "កត្តាកំណត់ដើម្បីឈានដល់ការសម្រេចសេចក្តីនៅឯសវនាការ"។ ដូច្នេះ បទដ្ឋានកម្រិតខ្ពស់ គឺជាចំណុចសំខាន់ខានមិនបាន ដើម្បីបញ្ចៀសកុំឱ្យបណ្តឹងសាទុក្ខកាន់តែថមថយនៅក្នុងសវនាការទីពីរ ដើម្បីកុំឱ្យពន្យារពេលដល់កិច្ចដំណើរការនីតិវិធីហួសហេតុ និងការលើកកម្ពស់ក្នុងការអនុវត្តរឿងក្តីដោយគ្មានប្រសិទ្ធភាព[5]។

4. អជតក ក៏បានរកឃើញផងដែរថា ខ្លួនមានអំណាចឆន្ទានុសិទ្ធិស្របតាមវិធាន១០៤(១) ដើម្បីទទួលយកភស្តុតាងថ្មី "ប្រសិនបើផលប្រយោជន៍នៃយុត្តិធម៌តម្រូវ ដោយផ្អែកលើកាលៈទេសៈជាក់លាក់នៃករណី"[6]។ ដើម្បីកំណត់ដូច្នេះ អង្គជំនុំជម្រះនឹងត្រូវពិចារណាថាតើ ភស្តុតាងនោះនឹងនាំទៅដល់ការស្វែងរកការពិតដែរឬអត់[7]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា "ប្រយោជន៍នៃយុត្តិធម៌" និង "កាលៈទេសៈជាក់លាក់នៃករណី" ចំបាច់ត្រូវបញ្ចូលសេចក្តីពិចារណាអំពីកត្តាទាំងបីដែល អជតក បានកំណត់អត្តសញ្ញាណថាពាក់ព័ន្ធទៅនឹងការពិចារណាអំពីភស្តុតាងថ្មី ដោយអនុលោមតាមវិធាន ១០៨(៧)។ លើសពីនេះ គេផ្តល់មូលហេតុថា វានឹងផ្តល់ផលបញ្ច្រាសត្រឡប់មកវិញ ប្រសិនបើអំណាចឆន្ទានុសិទ្ធិនេះត្រូវបានប្រើ រហូតដល់ធ្វើឱ្យងាកចេញពីគោលបំណងនៃវិធានដែលកំណត់ពី

---

[4] **F2/5** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, ២៩ ឧសភា ២០១៥, ត្រង់កថាខណ្ឌ ១៦។

[5] *រដ្ឋអាជ្ញា ទល់នឹង Kupreškić និងគូកន.*, IT-95-16-A, សេចក្តីសម្រេចលើញត្តិរបស់ Drago Josipović, Zoran Kupreškić និង Vlatko Kupreškić សុំឱ្យទទួលយកភស្តុតាងបន្ថែម អនុលោមតាមវិធាន១១៥ និងសុំឱ្យចាត់វិធានការសច្ចទស្សន៍តុលាការ អនុលោមវិធាន៩៤(ខ), ៨ ឧសភា ២០០១, ត្រង់កថាខណ្ឌ ៣។

[6] **F2/5** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, ២៩ ឧសភា ២០១៥, ត្រង់កថាខណ្ឌ ១៧។

[7] **F2/5** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, ២៩ ឧសភា ២០១៥, ត្រង់កថាខណ្ឌ ១៧។

បទដ្ឋានខ្ពស់សម្រាប់ការទទួលយកភស្តុតាងថ្មី ដែលមានចែងក្នុងវិធាន ១០៨(៧) *មានន័យថា* ជាការអនុញ្ញាតឲ្យករណីលើកលែងលេបត្របាក់យកវិធាននេះ។

5. បន្ទុកនៃការបង្ហាញថា ភស្តុតាងថ្មីនេះគឺអាចទទួលយកបានដើម្បីដាក់បញ្ចូលសម្រាប់បណ្តឹងសាទុក្ខ គឺពឹងផ្អែកទាំងស្រុងទៅលើភាគីស្នើសុំ[8]។ នួន ជា មិនបានផ្តល់អំណះអំណាងដែលមានសំអាងហេតុអំពីរបៀបថាហេតុអ្វីបានជាមាន "ប្រយោជន៍នៃយុត្តិធម៌" បើទទួលយកភស្តុតាងបន្ថែមដែលគាត់បានស្នើសម្រាប់បណ្តឹងសាទុក្ខនោះទេ។

## III. ចម្លើយតប

6. នួន ជា ស្នើឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ១-៩[9] និងឲ្យកោះហៅសាក្សី១ និង ២ មកផ្តល់សក្ខីកម្ម អនុលោមតាមវិធាន ១០៨(៧) និង ១០៤(១)[10]។ នួន ជា ស្នើឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី SCW-5 និងឧបសម្ព័ន្ធដែលពាក់ព័ន្ធរបស់កំណត់ហេតុនេះ និងស្តាប់សក្ខីកម្មសាក្សី 2-TCW-959, 2-TCW-960 និង 2-TCW-961 ដោយអនុលោមតាមវិធាន ១០៤(១)[11]។ សហព្រះរាជអាជ្ញានឹងលើកឯកសារ និងសាក្សីដែលបានស្នើឡើងនិមួយៗទាំងនេះខាងក្រោម ប៉ុន្តែជាដំបូង សហព្រះរាជអាជ្ញាសូមផ្តល់ការសង្កេតដែលពាក់ព័ន្ធជាទូទៅខ្លះៗសិន។

7. គ្មានកំណត់ហេតុស្តាប់ចម្លើយណាមួយ ឬសក្ខីកម្មសាក្សីណាម្នាក់ដែលបានស្នើឡើងមានភស្តុតាងដែល "អាចជាកត្តាកំណត់"ដើម្បីឈានដល់សាលក្រមឡើយ។ តាមពិត ភស្តុតាងភាគច្រើន មិនទាំងអស់ទេ ពីបុគ្គលម្នាក់ៗដែល នួន ជា បានបញ្ជាក់នៅក្នុងសំណើសុំភស្តុតាងបន្ថែមទីប្រាំរបស់

---

[8] សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, ២៩ ឧសភា ២០១៥, ត្រង់កថាខណ្ឌ ១៦។ *រដ្ឋអាជ្ញា ទល់នឹង* Kvocka *និងគូកន.*, សាលដីកាសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងបណ្តឹងឧទ្ធរណ៍ ស្នើឲ្យទទួលយកភស្តុតាងបន្ថែម អនុលោមតាមវិធាន១១៥, ១៦ កុម្ភៈ ២០១៤ (ដោយធ្វើការកត់សំគាល់ថា "ម្ចាស់បណ្តឹងឧទ្ធរណ៍ Prcac មិនបានកំណត់ថា[ភស្តុតាង]នោះ អាចជាកត្តាកំណត់ដើម្បីឈានដល់សេចក្តីសម្រេចនៅឯសវនាការទេ")។

[9] ដើម្បីភាពច្បាស់លាស់, សហព្រះរាជអាជ្ញាប្រើរហស្សនាមដូចគ្នាទៅនឹងរហស្សនាមដែល នួន ជា ប្រើនៅក្នុងការដាក់ឯកសាររបស់គាត់។

[10] **F2/7** សំណើសុំភស្តុតាងបន្ថែមទីប្រាំ, ត្រង់កថាខណ្ឌ៥៩-៦១។

[11] **F2/7** សំណើសុំភស្តុតាងបន្ថែមទីប្រាំ, ត្រង់កថាខណ្ឌ៦៦។

គាត់ មានតែការពាក់ព័ន្ធខ្សោយបំផុតទាក់ទងទៅនឹងព្រឹត្តិការណ៍នានា ដែលបានលើកក្នុងសាលក្រមនៃសំណុំរឿង០០២/០១ និងការពាក់ផ្អែកទៅលើការសន្និដ្ឋានបែបស្មានៗតែប៉ុណ្ណោះ។ នួន ជា ស្នើសុំភ័ស្តុតាងនេះទាក់ទងនឹងការកាត់ទោសគាត់ចំពោះការសម្លាប់ទាហាន និងរដ្ឋការ លន់ នល់ នៅទួលពោធិ៍ជ្រៃ ក្នុងខែមេសា ១៩៧៥។ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនោះ គាត់តវ៉ាថា ភ័ស្តុតាងនេះគឺពាក់ព័ន្ធនឹងគោលនយោបាយកំណត់គោលដៅអតីតទាហាន និងរដ្ឋការ លន់ នល់ បញ្ជាធ្វើឡើងដោយ រស់ ញឹម និងអ្នកផ្សេងទៀតនៅឯកិច្ចប្រជុំមួយធ្វើឡើងបន្ទាប់ពីការដណ្តើមបានខេត្តពោធិ៍សាត់ និងរចនាសម្ព័ន្ធឋានានុក្រមនៃសិទ្ធិអំណាចនៅក្នុង បកក[12]។

8. ជាបណ្តោះអាសន្ន គ្មានភ័ស្តុតាងណាមួយដែលបានស្នើឡើងដោយ នួន ជា មានសហសម្ព័ន្ធទៅនឹងចិរវេលានៃការសម្លាប់នៅទួលពោធិ៍ជ្រៃ ដែល នួន ជា ត្រូវបានផ្តន្ទាទោសហើយទេ ដូច្នេះគ្មានភ័ស្តុតាងណាមួយអាចជាកត្តាកំណត់ដើម្បីឈានដល់សាលក្រមឡើយ។

9. ជាសហកាលិក នួន ជា មិនបានលើកភ័ស្តុតាងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយណាមួយទាក់ទងនឹងទួលពោធិ៍ជ្រៃទេ គ្មានភ័ស្តុតាងដោះបន្ទុកទាក់ទងទៅនឹងគោលនយោបាយកំណត់គោលដៅលើអតីតរដ្ឋការ និងទាហាន លន់ នល់ ទេ និងក៏គ្មានភ័ស្តុតាងណាដែលជំទាស់ទៅនឹងការរកឃើញថា រចនាសម្ព័ន្ធឋានានុក្រមនៃសិទ្ធិអំណាច គឺមានរឹងមាំនៅក្នុងអំឡុងនៃព្រឹត្តការណ៍នៅទួលពោធិ៍ជ្រៃ ដែល នួន ជា និង ខៀវ សំផន ត្រូវបានកាត់ឱ្យជាប់ទោសរួចហើយនៅក្នុងសំណុំរឿង០០២/០១។ តាមពិតអង្គជំនុំជម្រះតុលាការកំពូលនឹងពិនិត្យមើលដោយគ្មានប្រយោជន៍ចំពោះសញ្ញាណ ដែលបានស្នើដើម្បីស្វែងរកភ័ស្តុតាងណាមួយបញ្ជាក់អំពីគោលយោបាយកំណត់គោលដៅរដ្ឋការ និងទាហានសាធារណរដ្ឋខ្មែរ មិនកើតចេញមកពីមជ្ឈិមបក្ស និងមិនត្រូវបានអនុវត្តដោយភូមិភាគរហូតដល់ពេលខ្មែរក្រហម ត្រូវបានផ្តួលរំលំ។

10. ការពិត ដោយផ្អែកលើសម្រង់ដែលបានបញ្ជាក់ដោយ នួន ជា ពីឯកសារ និងសាក្សីដែលបានដាក់ជូន គាត់ហាក់ដូចជាកំពុងតែស្នើថា ភ័ស្តុតាងណាក៏ដោយ តាំងពីពេលណាក៏ដោយដែល រស់ ញឹម ត្រូវបានចាប់ខ្លួន និងសម្លាប់ ដែលកងទ័ពភូមិភាគនិរតីធ្លាប់បានធ្វើការបោសសម្អាតភូមិភាគពាយ័ព្យឬ ដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាលរបស់ភូមិភាគពាយ័ព្យ គឺសុទ្ធតែមានសារៈសំខាន់គ្រប់គ្រាន់ទាំងអស់ដើម្បីទទួលយកជាភ័ស្តុតាងថ្មីសម្រាប់បណ្តឹងសាទុក្ខ។ ក៏ប៉ុន្តែ ពុំមានចំនួនព័ត៌មាន

[12] F2/7 សំណើសុំភ័ស្តុតាងបន្ថែមទីប្រាំ, គ្រង់កថាខណ្ឌ៥២-៥៤។

បន្ថែមនៅលើប្រធានបទណាមួយនៃប្រធានបទពាក់ព័ន្ធទាំងនេះ អាចនឹងធ្វើឱ្យមានការផ្លាស់ប្តូរចំពោះសាលក្រមឡើយ។

11. នួន ជា ក៏តវ៉ាផងដែរថា កំណត់ហេតុស្តាប់ចម្លើយទាំងប្រាំ និងឧបមស្ព័ន្ធមួយ គួរត្រូវបានទទួលយក យ៉ាងហោចណាស់ក៏ផ្នែកខ្លះដែរ ដោយសារវាពាក់ព័ន្ធទៅនឹង "ចំណុចសំខាន់បំផុតនៃសក្ខីកម្មរបស់សាក្សី SCW-5"[13]។ ចំពោះចំណុចផ្សេងទៀត នួន ជា បានសំដៅទៅលើកំណត់ហេតុស្តាប់ចម្លើយទាំងនោះថា កំពុងតែពាក់ព័ន្ធទៅនឹង "សក្ខីកម្មដែលគេរំពឹងទុក" របស់សាក្សី SCW-5[14] និង "ទំនងជាសក្ខីកម្ម"[15] របស់ SCW-5 និងថាកំណត់ហេតុស្តាប់ចម្លើយត្រូវបានដាក់ "មួយផ្នែកដើម្បីបន្ថែមកម្លាំង និងផ្ទៀងផ្ទាត់សក្ខីកម្មរបស់សាក្សី SCW-5"[16]។ ដូច្នេះ ពេលនេះ នួន ជា កំពុងស្នើឱ្យទទួលយកភ័ស្តុតាងថ្មីនៅលើបណ្តឹងសាទុក្ខ ដោយផ្អែកលើភាពពាក់ព័ន្ធស្មានៗរបស់ខ្លួន មិនចំពោះតែសាលក្រមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះភ័ស្តុតាងថ្មីផ្សេងៗទៀត ដែលបានទទួលយកសម្រាប់បណ្តឹងសាទុក្ខផងដែរ ហើយដូចគ្នានឹងសក្ខីកម្មរបស់សាក្សី SCW-5 ក្នុងសំណើសុំបន្ថែមភ័ស្តុតាងទីប្រាំត្រូវបានធ្វើឡើង គឺទាក់ទងទៅនឹងការស្មានអំពីថាតើភ័ស្តុតាងថ្មីណាខ្លះដែលនឹងមកដល់។ ការណ៍នេះ គឺបានដើរមកដល់កំណាត់ផ្លូវមួយវែងឆ្ងាយហួសពីបទដ្ឋានតឹងរ៉ឹងកម្រិតខ្ពស់សម្រាប់ភ័ស្តុតាងថ្មីលើបណ្តឹងសាទុក្ខ ដែលអង្គជំនុំជម្រះនេះបានដាក់ត្រឹមត្រូវហើយ។

12. លើសពីនេះទៀត ដោយសារតែ នួន ជា ពឹងផ្អែកទៅលើវិសាលភាពធំនៃទំនាក់ទំនងរវាងសក្ខីកម្មដែលរំពឹងទុករបស់សាក្សី SCW-5 អាច និងភាពពាក់ព័ន្ធនៃភ័ស្តុតាងដែលបានស្នើឱ្យទទួលយកតាមរយៈសំណើសុំបន្ថែមភ័ស្តុតាងទីប្រាំ ជាការត្រឹមត្រូវដែលត្រូវធ្វើការវាយតម្លៃទៅលើទាមទារដែលមាននៅក្នុងសំណើសុំបន្ថែមភ័ស្តុតាងទីប្រាំ ធៀបនឹងសក្ខីកម្មពិតប្រាកដដែលបានផ្តល់ដោយសាក្សី SCW-5។

13. ខាងក្រោមនេះ គឺជាអ្វីដែល នួន ជា បានរៀបរាប់អំពីសាក្សី SCW-5 នៅក្នុងសំណើសុំដំបូងរបស់គាត់ដើម្បីកោះហៅមកធ្វើជាសាក្សី៖

[13] **F2/7** សំណើសុំភ័ស្តុតាងបន្ថែមទីប្រាំ, គ្រង់កថាខណ្ឌ៥។

[14] **F2/7** សំណើសុំភ័ស្តុតាងបន្ថែមទីប្រាំ, គ្រង់កថាខណ្ឌ៦។

[15] **F2/7** សំណើសុំភ័ស្តុតាងបន្ថែមទីប្រាំ, គ្រង់កថាខណ្ឌ៦។

[16] **F2/7** សំណើសុំភ័ស្តុតាងបន្ថែមទីប្រាំ, គ្រង់កថាខណ្ឌ៦២។

... [សាក្សី SCW-5] បង្ហាញថា គាត់គឺជាសាក្សីដែលល្អបំផុត សម្រាប់ធ្វើការវិនិច្ឆ័យលើការការពារក្តីទូលំទូលាយជាគន្លឹះរបស់ នួន ជា នៅក្នុងផ្នែកទាំងពីរនៃសំណុំរឿង០០២៖ បក្សកុម្មុយនីស្តកម្ពុជា គឺជាបក្សដែលមានការបែកបាក់យ៉ាងជ្រាលជ្រៅ នៅកម្រិតកំពូលរបស់ខ្លួន ព្រោះមេដឹកនាំបក្សខ្លះ ដែលក្នុងចំណោមពួកគេ គឺឪពុកធម៌របស់ ទាត់ - បានប្រឆាំងនឹងមេដឹកនាំដែលល្បីក្នុងជម្លោះដណ្តើមអំណាចយ៉ាងជូរចត់[17]។

14. ខាងក្រោមនេះ គឺជាអ្វីដែល នួន ជា បានរៀបរាប់អំពីសក្ខីកម្មដែលរំពឹងទុករបស់សាក្សី SCW-5 ក្នុងសំណើសុំបន្ថែមភស្តុតាងរបស់គាត់ ដើម្បីគាំទ្រដល់សំណើរបស់គាត់សម្រាប់សាក្សី "បញ្ជាក់បន្ថែម" ថា៖

សាក្សី SCW-5 ក៏ជាសាក្សីសំខាន់មួយរូបផងដែរ ពាក់ព័ន្ធរចនាសម្ព័ន្ធបក្សកុម្មុនីស្តកម្ពុជា និងប្រភពដើម វិសាលភាព ព្រមទាំងលក្ខណៈនៃជម្លោះប្រដាប់អាវុធនៅក្នុងបក្សកុម្មុនីស្តកម្ពុជា ហើយសក្ខីកម្មរបស់គាត់បានគាំទ្រដល់សារណារបស់មេធាវីការពារក្តីដែលថា ថ្នាក់ដឹកនាំនៅភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ា បានបង្កើតបក្សប្រឆាំងរួមគ្នាមួយ ប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា ចាប់តាំងពីដើមឆ្នាំ១៩៧៦ និងប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានទទួលស្គាល់យ៉ាងទូទំទូលាយ ដែល សោ ភឹម និង រស់ ញឹម បានបំរើក្នុងឋានៈជាមន្ត្រីជាន់ខ្ពស់។ សាក្សី SCW-5 រៀបរាប់ថា ខ្លួនគាត់ផ្ទាល់បានបណ្តុះគ្រប់ពូជនៃជម្លោះប្រដាប់អាវុធដោយចំហរនេះ តាំងពីឆ្នាំ១៩៧៥ មកម្ល៉េះ[18]។

15. ប៉ុន្តែ សក្ខីកម្មពិតរបស់សាក្សី SCW-5 ផ្ទុយគ្នាស្រឡះពីការសន្មតជាមូលដ្ឋាននៃសំណើសុំភស្តុតាងថ្មីនេះ ដោយសារសក្ខីកម្មរបស់គាត់បំបាត់ចោលទាំងស្រុងនូវការស្មានណាមួយដែលថា រស់ ញឹម បានស្ថិតនៅក្នុងការធ្វើការបះបោរប្រឆាំងនឹងមជ្ឈិមបក្សក្នុងឆ្នាំ១៩៧៥ SCW-5 ដំបូងបាននិយាយថា មិនបានសម្រេចរត់ចោលអង្គការទេ រហូតដល់ឆ្នាំ១៩៧៨ ទើបមានការប៉ុនប៉ងចាប់ខ្លួនគាត់[19] បន្ទាប់មកគេសួរគាត់ថា៖

---

[17] **F2/4** សំណើលើកទីបី សុំឲ្យធ្វើការពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១, ២៥ វិច្ឆិកា ២០១៤, ត្រង់កថាខណ្ឌ២៦ (សង្កត់ន័យដើម)។

[18] **F2/7** សំណើសុំភស្តុតាងបន្ថែមទីប្រាំ, ត្រង់កថាខណ្ឌ៩។

[19] ខណ្ឌពង្រាងប្រតិចារឹក ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៥ នៅម៉ោង 10.58.29។

[មេធាវីការពារក្តី នួន ជា]:... តើលោកដឹងថា ពេលណាដែលផែនការត្រូវបានធ្វើឡើងជាលើកដំបូងដើម្បីបះបោរដែរទេ? និងថា តើអ្នកណាជាអ្នកនៅពីក្រោយផែនការបះបោរនេះ?

[សាក្សី SCW-5]: ផែនការបះបោរនេះ គឺគ្មានអ្នកណានៅពីក្រោយទេ គឺធ្វើដោយខ្លួនឯង ដោយថារស់នៅក្នុងរបបអង្គការហ្នឹងលែងបានហើយ ព្រោះបាត់មិត្តជាច្រើន យុទ្ធមិត្តជាច្រើន។ ពួកគេត្រូវបានគេហៅឲ្យទៅរៀននៅភ្នំពេញ ហើយក៏បាត់ខ្លួនតែម្តង។ ក្រោយមកខ្ញុំបានដឹងថា ពួកគេចង់ចាប់ខ្ញុំ និងដោយសារទេវតាជួយ ចាប់ខ្ញុំមិនបាន។ ខ្ញុំសម្រេចចិត្តថា យកអាវុធចំនួន២០០០ដើមហ្នឹងដើម្បីចាប់ផ្តើមបះបោរ។ ខ្ញុំបានអង្វរ តាប៉េត តាញឹម និងតាៗផ្សេងទៀត ឲ្យចាប់ផ្តើមធ្វើការបះបោរប្រឆាំងអង្គការក្នុងពេលនោះ[20]។

16. សាក្សី SCW-5 ធ្លាប់បានពន្យល់ពីមុនអំពីប្រតិកម្មរបស់ រស់ ញឹម នៅពេលគាត់ "សុំអង្វរ" គាត់ឲ្យធ្វើការបះបោរ: "ឪពុកចិញ្ចឹមខ្ញុំបានពន្យល់ប្រាប់ខ្ញុំថា គាត់មិនធ្វើអ្វីៗតក់ក្រហល់ទេ ហើយគាត់ប្រាប់ខ្ញុំឲ្យអត់ធ្មត់"[21]។

17. ដោយមិនពេញចិត្ត មេធាវីការពារក្តី នួន ជា បានព្យាយាមម្តងទៀត៖

[មេធាវីការពារក្តី នួន ជា]: លោកសាក្សី អ្វីៗទាំងដែលលោកបានជំរាបជូន គួឲ្យចាប់អារម្មណ៍មែនទែន។ ប៉ុន្តែ តើវាមិនពិតទេឬ ខ្ញុំសួរសំណួរនេះទៅលោក ដែលមានពេលណាមួយនៅក្នុងរដូវក្តៅ ៧៥, សីហា ៧៥, ដែលឪពុកចិញ្ចឹមរបស់លោកជាមួយនឹង សោ ភឹម, វន វ៉េត, អាចមាន កុយ ធួន ដែរ ចាប់ផ្តើមនិយាយគ្នា - ចាប់ផ្តើមមានផែនការបះបោរប្រឆាំងរដ្ឋាភិបាល ឬរដ្ឋាភិបាលដែលគ្រោងនឹងបង្កើតឡើងចាប់ៗខាងមុខ? តើនេះជាការត្រឹមត្រូវដែរទេ?

[សាក្សី SCW-5]: ... តាមពិត គ្មានផែនការបះបោរអីទេ[22]។

18. មេធាវីការពារក្តី នួន ជា ជជីកថា៖

---

[20] សេចក្តីព្រាងប្រតិចារឹក, ៦ កក្កដា ២០១៥, ត្រង់ 11.00.28-11.01.05; សូមមើលផងដែរ *ក្នុងឯកសារដដែល* ត្រង់ 11.39.53 ។

[21] សេចក្តីព្រាងប្រតិចារឹក, ៦ កក្កដា ២០១៥, ត្រង់ 10.58.29។

[22] សេចក្តីព្រាងប្រតិចារឹក, ៦ កក្កដា ២០១៥, ត្រង់ 11.01.15។

[មេធាវីការពារក្ដី នួន ជា]: មានផែនការ - តើលោកដឹងទេថា បើមានផែនការ នៅពេលណាមួយ ដើម្បីធ្វើឃាត ប៉ុល ពត ដើម្បីធ្វើវិទ្ធង្សនាបដិវត្តតាមរយៈការផ្សព្វផ្សាយភាពវឹកវរទាំងខាងក្នុង និង ខាងក្រៅ - ឧទាហរណ៍ តាមរយៈការធ្វើសង្គ្រាមក្លែងក្លាយជាមួយប្រទេសថៃ - ជាចុងក្រោយ គឺ ដើម្បីធ្វើរដ្ឋប្រហារ តើលោកបានដឹងអ្វីខ្លះអំពីផែនការនេះទេ? តើផែនការនេះមានមែនដែរឬទេ ចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៥?

[SCW-5]: ទេ, ខ្ញុំមិនបានដឹងអំពីរឿងនេះទេ។

[មេធាវីការពារក្ដី នួន ជា]: តើលោកធ្លាប់បានឮអំពីផែនការបញ្ចូលកម្លាំងពីភូមិភាគបូព៌ា និងអតីត ភូមិភាគឧត្តរ ដើម្បីវាយយកព្រលានយន្តហោះពោធិ៍ចិនតុង ដើម្បីវាយស្ថានីយវិទ្យុ វិទ្យុភ្នំពេញនៅ ក្នុងពេលណាមួយនៅដើមឆ្នាំ១៩៧៧ ដែរឬទេ?

[SCW-5]: ទេ, ខ្ញុំមិនបានដឹងអំពីរឿងនេះទេ[23]។

19. នៅពេលដែល SCW-5 ត្រូវបានសួរម្ដងទៀតអំពី "ផែនការប្រមូលកងទ័ពវាងខាងបូព៌ា" ហ្នឹង គាត់បានពន្យល់ថា គាត់ពិតជាបានទាក់ទងជាមួយនឹងកម្លាំងផ្សេងៗទៀតមែន ប៉ុន្តែការទាក់ទង នោះកើតឡើងក្រោយពេលរបបខ្មែរក្រហមបានដួលរលំហើយ៖

> [មេធាវីការពារក្ដី នួន ជា]៖ ហើយថាតើនៅពេលនោះ លោកបានទំនាក់ទំនងជាមួយកងទ័ព ភូមិភាគបូព៌ាដែលដឹកនាំដោយ ហេង សំរិន ដែរឬទេ? ដែលថាលោកជាមួយនឹងកម្លាំងរបស់ ហេង សំរិន នោះបានប្រយុទ្ធជាមួយនឹងកងទ័ពភូមិភាគនិរតី។ តើត្រឹមត្រូវដែរឬទេ?
>
> [SCW-5]៖ បាទ ការទាក់ទងជាមួយនឹងលោកតា ហេង សំរិន ខាងរណសិរ្សសាមគ្គីសង្គ្រោះ ជាតិនោះគឺក្រោយពេលដែលគាត់ទៅដល់កងទ័ពរណសិរ្សទៅដល់ខេត្តបាត់ដំបងទេ។ ... ខ្ញុំក៏ បានទាក់ទងគ្នា នៅហ្នឹងបាត់ដំបងទៅ ខ្ញុំមិនទាក់ទងនៅឯបូព៌ាទេបាទ។

[23] សេចក្ដីព្រាងប្រតិចារឹក, ៦ កក្កដា ២០១៥, ត្រង់ 11.05.26។

20. នួន ជា ក៏បានប្រាប់ អជតក ថា សក្ខីកម្មរបស់ SCW-5 មានលក្ខណៈប្រកដប្រជា ដោយសារគាត់ "រៀបរាប់ថាបានផ្តួចផ្តើមជម្លោះប្រដាប់អាវុធជាចំហរដោយផ្ទាល់នេះតាំងពីឆ្នាំ១៩៧៥មកម្លេះ" ដោយការធ្វើឃ្លាំង និងរក្សាទុកអាវុធនៅទីនោះ[24]។ ការលើកឡើងនេះត្រូវបានសួរទៅកាន់ SCW-5 នៅក្នុងសវនាការក្នុងការឆ្លើយដូចខាងក្រោម៖

> [មេធាវីការពារក្តី នួន ជា]៖ តើនេះ គឺជាគោលបំណងតាំងពីដើមរបស់លោក ក្នុងការលាក់អាវុធហ្នឹង ដើម្បីឲ្យលោក រស់ ញឹម លោក និងអ្នកដទៃទៀត អាចយកអាវុធនេះមកប្រើប្រាស់ក្នុងការបះបោរប្រឆាំងនឹង ប៉ុល ពត ដែរ ឬយ៉ាងណា?
> [SCW-5]៖ បាទ កាលនោះ គឺវាអត់មានលាក់អាវុធ មានបំណងយ៉ាងម៉េច[25]។
> ...
> [SCW-5]៖ គឺអាវុធនេះ មិនមែនលាក់ទុកសម្រាប់តស៊ូប្រឆាំងជាមួយ ប៉ុល ពត ទេ ដំបូង គឺទុកដាក់ឲ្យបានល្អប៉ុណ្ណឹងទេ[26]។

21. ក្រោយមកទៀត SCW-5 បានបញ្ជាក់បន្ថែមទៀតថា រស់ ញឹម មិនបានណែនាំឲ្យលាក់អាវុធនោះទេ៖

> [មេធាវីការពារក្តី ខៀវ សំផន]៖ តើ រស់ ញឹម មានបានណែនាំលោកពីរបៀបលាក់អាវុធហ្នឹងដូចម្តេចទេ?
> [SCW-5]៖ បាទ អត់បានណែនាំទេ គឺគ្រាន់តែថា រៀបចំទុកដាក់ ធ្វើឃ្លាំងទុកឲ្យស្អាតប៉ុណ្ណឹង[27]។

22. ទោះបីជា SCW-5 បានបដិសេធយ៉ាងមុតមាំជាច្រើនដង "សាក្សីដែលល្អបំផុតសម្រាប់ធ្វើការវិនិច្ឆ័យលើការការពារក្តីទូលំទូលាយជាគន្លឹះរបស់ នួន ជា នៅក្នុងផ្នែកទាំងពីរនៃសំណុំរឿង០០២"[28] នៃ

---

[24] F2/4 សំណើលើកទីបី សុំឲ្យធ្វើការពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទងបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤ ត្រង់កថាខណ្ឌ១៩។

[25] សេចក្តីព្រៀងប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ត្រង់ 10.47.25-10.49.10 ។

[26] សេចក្តីព្រៀងប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ត្រង់ 10.55.17 ។

[27] សេចក្តីព្រៀងប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ត្រង់ 14.55.41-14.58.52។

ក្រុមខ្មែរក្រហម ដែលបានបែកបាក់ក្នុងទំនាស់ដោយមិនបានអនុវត្តតាមលំដាប់ថ្នាក់នៃការបញ្ជា យ៉ាងណាក៏ដោយ ក៏សាក្សីនេះពិតជាបានផ្តល់នូវ "ព័ត៌មានជាសត្យានុម័តទាក់ទងនឹងគោលនយោបាយរបស់ ប.ក.ក ប្រឆាំងនឹងមន្ត្រី និងទាហានរបស់សាធារណរដ្ឋខ្មែរ"[29]។ ជាការឆ្លើយតបទៅនឹងសំណួរពីចៅក្រម ថាតើគាត់បានដឹង "អំពីគោលនយោបាយណាមួយពាក់ព័ន្ធទៅនឹងទាហាន លន់ នល់" SCW-5 ឆ្លើយតបថា គាត់បានស្តាប់ឮអំពីគោលនយោបាយនោះត្រូវបានគេពិភាក្សានៅក្នុងការប្រជុំមួយ៖ "បាទ គោលនយោបាយខ្មែរក្រហមខ្ញុំបានធ្លាប់ឮខ្លះៗដែរ ប៉ុន្តែវាមិនច្បាស់លាស់ដែរទេ គឺគេថាកម្ទេច វាប៉ុណ្ណឹងបាទ។ កម្ទេចពួកអតីតចក្រពត្តិ កម្ទេចពួកសក្តិភូមិអ៊ីចឹងទៅ ហ្នឹងឮអ៊ីចឹងទៅ"[30]។ នៅពេលសួរអំពីប្រភពដើមនៃគោលនយោបាយនេះ គាត់បានឆ្លើយថា "ថាថ្នាក់លើ គោលនយោបាយថ្នាក់លើ ថ្នាក់លើបញ្ជា"[31] និងបានបញ្ជាក់ថា "បាទ បើថ្នាក់លើភូមិភាគ មានតែមកមជ្ឈិមទេបាទ ព្រោះភូមិភាគនិយាយអ៊ីចឹងបាទ"[32]។

23. ជាចុងក្រោយ សហព្រះរាជអាជ្ញាបញ្ជាក់ឡើងវិញនូវចំណុចដែលបានលើកឡើងក្នុងចម្លើយតបរបស់ខ្លួន ទៅនឹងសំណើលើកទីបួនរបស់ នួន ជា សុំឱ្យទទួលយកភស្តុតាងបន្ថែម[33] ថាវាមិនស្ថិតនៅក្នុងផលប្រយោជន៍យុត្តិធម៌ និងមិនជួយដល់ការស្វែងរកការពិតទេ ក្នុងការទទួលយកភ័ស្តុតាងជ្រើសរើសថ្មីៗ ដែលត្រូវបានស្នើឡើងដោយភាគីមួយនោះ ដោយគ្រាន់តែទាក់ទងទៅនឹងបញ្ហាទាំងនេះនោះ ពីព្រោះភ័ស្តុតាងថ្មីដែលបានទទួលយកតាមរយៈវិធីបែបនេះ នឹងនាំឱ្យមានទស្សនៈមិនត្រឹមត្រូវជាប់មកជាមួយនឹងការពិត។ បើសិនជាអង្គជំនុំជម្រះសម្រេចថាវាស្ថិតនៅក្នុងផលប្រយោជន៍យុត្តិធម៌ ក្នុងការបើកឡើងវិញនូវការស្វែងរកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងនោះ ភាគីទាំងអស់គួរត្រូវបានជូនដំណឹងឱ្យដាក់ភ័ស្តុតាងបន្ថែមទៀត ពាក់ព័ន្ធទៅនឹងចំណុចដែលស្ថិតក្នុងការជំទាស់នេះ។

---

[28] F2/4 សំណើលើកទីបី សុំឱ្យធ្វើការពិចារណា និងទទួលយកភ័ស្តុតាងបន្ថែម ទាក់ទងបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤ ត្រង់កថាខណ្ឌ ២៦។

[29] F2/5 សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ត្រង់កថាខណ្ឌ២០។

[30] សេចក្តីព្រៀងប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ត្រង់ 16.45.52។

[31] សេចក្តីព្រៀងប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ត្រង់ 16.50.08។

[32] សេចក្តីព្រៀងប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ត្រង់ 16.52.19។

[33] F2/6/2 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៤ របស់ នួន ជា ស្នើសុំឱ្យពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥។

## *ក. សំណើសុំកំណត់ហេតុស្តាប់ចម្លើយ និងសក្ខីកម្មរបស់សាក្សីលេខ ១*

24. នួន ជា ស្វែងរកឱ្យមានការទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីលេខ ១[34] និងឱ្យមានការកោះហៅសាក្សីនោះមកផ្តល់សក្ខីកម្ម[35]។ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងសំណើទាំងពីរនេះ។

25. ភ័ស្តុតាងដែលបានផ្តល់ឱ្យដោយសាក្សីលេខ១ មិនមែនជាកត្តាកំណត់នៅក្នុងសាលក្រមទេ ហើយក៏មិនជួយស្វែងរកការពិតនោះដែរ។ សាក្សីនេះមិនបាននិយាយអំពីទួលពោធិ៍ជ្រៃ និងមិនបានផ្តល់ភ័ស្តុតាងណាមួយដែលជំទាស់ចំពោះការរកឃើញនៃរច្ចនាសម្ព័ន្ធគ្រប់គ្រងអំណាចជាធរមាន នៅពេលដែលពាក់ព័ន្ធនោះទេ ឬគោលនយោបាយដាក់គោលដៅលើអតីតទាហាន និងមន្ត្រី លន់ នល់។ ដូចដែល នួន ជា កត់សម្គាល់ថា សាក្សីលេខ១ មិនបាន[redacted] ទេ រហូតមកទល់ឆ្នាំ១៩៧៦[36] ដែលជាពេលយូរក្រោយព្រឹត្តិការណ៍នៅ ទួលពោធិ៍ជ្រៃ។

26. នួន ជា សង្កត់ធ្ងន់លើចម្លើយរបស់សាក្សីលេខ១ ក្នុងន័យដែលថាក្នុងឆ្នាំ១៩៧៧ សាក្សីនេះបានអមដំណើរជាមួយ រស់ ញឹម ដើម្បីដឹកសម្លៀកបំពាក់យោធា ដែល រស់ ញឹម បានប្រាប់គាត់ថាមកពីវៀតណាម ពីកន្លែងដែលនៅក្បែរព្រំដែនវៀតណាម មកកាន់មន្ទីររបស់ រស់ ញឹម[37]។ នួន ជា ក៏បានសង្កត់ធ្ងន់លើការអះអាងរបស់សាក្សីលេខ១ ដែលថា នៅពេលដែលរូបគាត់ត្រូវបានឃុំខ្លួន និងសួរចម្លើយ គាត់ត្រូវបានសួរអំពីការធ្វើដំណើរទៅវៀតណាមជាមួយនឹង រស់ ញឹម[38]។ តាមពិតដូចដែលអង្គជំនុំជម្រះនឹងរំលឹកឡើងវិញ ផ្នែកទាំងឡាយនៃសម្រង់របស់កំណត់ហេតុស្តាប់ចម្លើយនេះ ត្រូវបានអានឱ្យ SCW-5 ស្តាប់ ក្នុងពេលផ្តល់សក្ខីកម្មរបស់គាត់រួចហើយ។ ក្រុមមេធាវីការពារក្តី នួន ជា បានសួរ SCW-5 ថា៖ "តើលោកដឹងទេហេតុអ្វី?"[39]។ សាក្សីបានឆ្លើយថា៖

---

[34] **E319/19.3.107** កំណត់ហេតុនៃការស្តាប់ចម្លើយ [សាក្សីលេខ១] ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣។

[35] **F2/7** សំណើទីប្រាំសុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ១៤។

[36] **F2/7** សំណើទីប្រាំសុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ១៦។

[37] **F2/7** សំណើទីប្រាំសុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ១៦។

[38] **F2/7** សំណើទីប្រាំសុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ១៨។

[39] សេចក្តីព្រៀងប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ត្រង់ at 11.13.19។

បាទ ខ្ញុំមិនដែលឃើញ ហើយក៏មិនដែលឮ មិនដែលឃើញសម្លៀកបំពាក់ពីរៀតណាម។ មានដែរកាត់ខោអាវដោយរោងចក្រតម្បាញខេត្តបាត់ដំបងខ្លួនឯង ហើយជ្រលក់ផ្លែមាក់ក្លឿ ជ្រលក់ស្លឹកសង្កែ ដើមសង្កែ ជ្រលក់ស្លឹកស្នួល បុកជ្រលក់ឲ្យវាខ្មៅៗទៅ ប៉ុណ្ណឹង។ ហ្នឹងយកខោអាវពីក្រៅមកអត់មានទេបាទ[40]។

27. សម្រង់ផ្សេងៗទៀត ដែល នួន ជា ជ្រើសរើសពីការស្តាប់ចម្លើយរបស់សាក្សីលេខ១ បង្ហាញអំពីការចាប់ផ្តើមទូលំទូលាយនៃអ្វីដែលគាត់ជឿជាក់ថាពាក់ព័ន្ធ ដើម្បីទទួលយកជាភស្តុតាងថ្មីក្នុងបណ្តឹងសាទុក្ខ។ គាត់ស្នើឲ្យមានការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សីលេខ១ និងការកោះហៅគាត់ឲ្យធ្វើជាសាក្សី ដោយការបញ្ជាក់លើព័ត៌មានដែលគាត់បាននិយាយអំពី៖ ការចាប់ខ្លួន និងការសម្លាប់ រស់ ញឹម នៅចុងឆ្នាំ១៩៧៨[41] ការមកដល់ភូមិភាគពាយ័ព្យរបស់កងកម្លាំងភូមិភាគនិរតីក្នុងឆ្នាំ១៩៧៧ និងការបោសសំអាតភូមិភាគពាយ័ព្យជាបន្តបន្ទាប់នៅចុងឆ្នាំ១៩៧៨[42] ព័ត៌មានទាក់ទងទៅនឹងគ្រួសាររបស់ រស់ ញឹម[43] និងព័ត៌មានទាក់ទងនឹង "ប្រតិបត្តិការរបស់ភូមិភាគពាយ័ព្យ"[44]។ នួន ជា បានអនុវត្តវិធីសាស្រ្តទូលំទូលាយស្រដៀងគ្នានេះ ចំពោះកំណត់ហេតុនៃការស្តាប់ចម្លើយផ្សេងៗទៀត ដូចដែលអង្គជំនុំជម្រះអាចឃើញយ៉ាងច្បាស់នៅក្នុងការពិនិត្យឡើងវិញនៃព័ត៌មានសំខាន់ៗនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីដែល នួន ជា បានគូសបញ្ជាក់ នៅក្នុងសំណើសុំឲ្យទទួលយកភ័ស្តុតាងបន្ថែមលើកទីប្រាំ ប៉ុន្តែដើម្បីចៀសវាងនូវការលើកឡើងច្រំដែលមិនចាំបាច់នោះ សហព្រះរាជអាជ្ញានឹងមិនធ្វើការសង្កេតស្រដៀងគ្នានេះពាក់ព័ន្ធទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយផ្សេៗទៀតដែលបានស្នើឡើងនោះទេ។

28. នួន ជា មិនមានបំណងបង្ហាញឲ្យឃើញថាតើផ្នែកជាក់លាក់នៃព័ត៌មានដែលគាត់បានដកស្រង់ និងសង្ខេបពាក់ព័ន្ធនឹងឯកសារនេះ ជាកត្តាកំណត់នៅក្នុងសាលក្រមដោយរបៀបណានោះទេ។ ផ្ទុយទៅវិញ នៅក្នុងផ្នែកនៃកថាខណ្ឌទាំងបីដែលពោពេញទៅដោយឃ្លាទូលំទូលាយច្រើននោះ គាត់បែរជាលើកឡើងដោយអះអាងអំពីរបៀបដែលកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំងបួន និងសាក្សីទាំងបីរូបដែលបានស្នើឡើងដោយឈរលើមូលដ្ឋាន សៀវភៅ *Behind the Killing Fields*

---

[40] សេចក្តីព្រៀងប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ត្រង់ at 11.13.19។

[41] **F2/7** សំណើទីប្រាំសុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ១៧។

[42] **F2/7** សំណើទីប្រាំសុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ១៩-២០។

[43] **F2/7** សំណើទីប្រាំសុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ២១។

[44] **F2/7** សំណើទីប្រាំសុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ២២។

ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទៅវិញ។ នៅក្នុងភាពច្របូកច្របល់នៃព័ត៌មានសង្ខេបនេះ កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សីលេខ១ ត្រូវបានបញ្ជាក់លើកទីមួយជាក់លាក់សម្រាប់តម្លៃភ័ស្តុតាងដូចខាងក្រោមនេះ៖ ថា គាត់ "ស៊ីសង្វាក់គ្នាជាក់លាក់ជាមួយនឹងការរៀបរាប់របស់សាក្សី SCW-5 និងសាក្សីមួយចំនួនផ្សេងទៀតរួមទាំង [redacted] ដែលបានលើកឡើងថា កម្មាភិបាលដឹកនាំនៅក្នុងភូមិភាគពាយ័ព្យ និងបូព៌ាបានបង្កើតក្រុមមួយរួមគ្នាប្រឆាំងនឹង បកក"[45]។ ប៉ុន្តែ ដូចដែលបានបង្ហាញ សាក្សី SCW-5 មិនបានផ្តល់ព័ត៌មានបែបនេះនោះទេ។ ជាងនេះទៀត នួន ជា មិនបានយោងសំអាងលើភ័ស្តុតាងក្នុងសំណុំរឿងដែលផ្តល់ឱ្យដោយ [redacted] ដែលរូបគាត់បានយោងទៅលើនោះទេ (ហើយបុគ្គលទាំងនេះក៏មិនបានផ្តល់សក្ខីកម្មនោះដែរ) និងសំខាន់ជាងគេបំផុតនោះ កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីលេខ១ មិនមានផ្តល់ភ័ស្តុតាងអំពី "ក្រុមមួយរួមគ្នាប្រឆាំងនឹងបកក" នោះដែរ។

29. នួន ជា ក៏បានអះអាងថា សាក្សីលេខ១ អាចមានលទ្ធភាព៖ "ផ្តល់ឧទាហរណ៍ជាក់លាក់អំពីវិធានាការយ៉ាងសកម្ម ដែលបានធ្វើឡើងចំពោះការបះបោរ និង/ឬ ការក្បត់ជាតិនៅក្នុងភូមិភាគពាយ័ព្យ។ សាក្សីទីមួយ បានរៀបរាប់អំពីហេតុការណ៍ដែលគាត់បានឃើញផ្ទាល់ភ្នែកនៅពេលគាត់អមដំណើររស់ ញឹម ទៅកាន់ព្រំដែនវៀតណាមដើម្បីប្រមូលឯកសណ្ឋានយោធាពីវៀតណាម"[46]។ នួន ជា លើកឡើងថា ឧទាហរណ៍នេះ "មិនគ្រាន់តែផ្តល់ទម្ងន់បន្ថែមលើការរៀបរាប់របស់សាក្សី SCW-5 អំពីការបង្កើតឃ្លាំងអាវុធនៅក្នុងព្រៃនៅដើមឆ្នាំ១៩៧៥ ប៉ុណ្ណោះទេ ប៉ុន្តែក៏ថែមទាំងបានចោទប្រកាន់អំពីការបង្កើត និងការចូលរួមនៅក្នុងចលនាខ្មែរសផងដែរ"[47]។ ប៉ុន្តែទោះបីជាដូចអ្វីដែល នួន ជា បានលើកឡើង ដែលថាការប្រមូលសម្លៀកបំពាក់ដែល រស់ ញឹម ប្រហែលជាបានប្រាប់សាក្សីលេខ១ ថា "យកមកពីយួន"[48] គឺជា "ជំហានទៅរកការបះបោរ"នោះ[49] រឿងនេះកើតឡើងក្នុងឆ្នាំ១៩៧៧[50] រយៈពេលយូរក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ។ ជាងនេះទៀត ដូចដែលបាន

[45] **F2/7** សំណើទីប្រាំសុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ៥៥។

[46] **F2/7** សំណើទីប្រាំសុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ៥៦។

[47] **F2/7** សំណើទីប្រាំសុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ៥៦។

[48] **F2/7** សំណើទីប្រាំសុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ១៦។

[49] សហព្រះរាជអាជ្ញា កត់សម្គាល់ឃើញថាសាក្សីលេខ១ បានថ្លែងថា "ខ្ញុំមិនដឹងថាគេយកមកឱ្យនរណាទេ..."។ **E319/19.3.107** កំណត់ហេតុនៃការស្តាប់ចម្លើយ[សាក្សីលេខ១], ៣១ តុលា ២០១៣, ត្រង់ ឆ.6។

[50] **F2/7** សំណើទីប្រាំសុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ១៦។

ដកស្រង់ខាងលើ ឥឡូវយើងដឹងថា សក្ខីកម្មរបស់ SCW-5 បញ្ជាក់ថាមិនមែនគាត់ទេដែលបានបង្កើត "ឃ្លាំងអាវុធ" ដែលមានទំនាក់ទំនងជាមួយនឹងការបះបោរណាមួយនោះ ប៉ុន្តែថា៖ ១) អាវុធទាំងនោះមិនមែនរក្សាទុកដើម្បីធ្វើការបះបោរនោះទេ និង ២) មិនមានផែនការបះបោរដែលរស់ ញឹម ជាប់ពាក់ព័ន្ធនោះដែរ។

30. លើកលែងកត្តាកំណត់ក្នុងសាលក្រម ទឡ្ហីករណ៍ដែលនៅសល់តែមួយគត់ដែល នួន ជា អះអាងចំពោះភ័ស្តុតាងរបស់សាក្សីលេខ១ ថាពាក់ព័ន្ធនោះ (ដូចដែលគាត់បានអះអាងចំពោះសាក្សីទាំងបួនរូបនៃសំណុំរឿង០០៤) គឺផ្អែកលើកត្តាកំណត់មួយគត់ក្នុងសាលក្រម គឺមិនច្បាស់លាស់ និងមិនពាក់ព័ន្ធទៅនឹង "ការជួយលាតត្រដាងនូវហេតុការណ៍ពិតបិទបាំងនៅក្នុងភូមិភាគពាយ័ព្យរហូតមកដល់ពេលនេះ" "ពន្យល់លម្អិតថាតើកម្មាភិបាលភូមិភាគនិរតីបានមកដល់ភូមិភាគពាយ័ព្យដោយរបៀបណា ហើយបន្ទាប់ពីពេលនោះមក ថាតើពួកគេបានចាប់ផ្តើមចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យរបៀបណាផងដែរ" និង "ពន្យល់ស៊ីជម្រៅអំពីរចនាសម្ព័ន្ធភូមិភាគពាយ័ព្យ បង្ហាញអត្តសញ្ញាណសមាជិកថ្នាក់ដឹកនាំរបស់ភូមិភាគនេះ និងរៀបរាប់លម្អិតអំពីជោគវាសនានៃមេដឹកនាំផ្សេងទៀត"[51]។ ការបង្ហាញមិនច្បាស់ និងសើៗបែបនេះ ពិតជាមិនមានតម្លៃអនុញ្ញាតឲ្យមានការទទួលយកភ័ស្តុតាងថ្មីលើបណ្តឹងសាទុក្ខក្រោមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះបានទេ។

### ខ. កំណត់ហេតុស្តាប់ចម្លើយ និងសក្ខីកម្មសាក្សីលេខ២

31. នួន ជា បានស្វែងរកការទទួលយកកំណត់ហេតុស្តាប់ចម្លើយ[52] សាក្សីលេខ២ និងឲ្យមានការកោះហៅសាក្សីនេះមកផ្តល់សក្ខីកម្ម[53]។ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងសំណើទាំងពីរនេះ។

32. ភ័ស្តុតាងដែលផ្តល់ឲ្យដោយសាក្សីលេខ២ មិនមែនជាកត្តាកំណត់នៅក្នុងសាលក្រមនោះទេ និងមិនមែនជាជំនួយក្នុងការស្វែងរកយុត្តិធម៌ដែរ។ សាក្សីលេខ២ មិនបាននិយាយអំពីទួលពោធិ៍ជ្រៃ ឬការជម្លៀសប្រជាជនដោយបង្ខំ ដែលជាប្រធានបទនៃសំណុំរឿងលេខ០០២/០១។ សាក្សីនេះមិនផ្តល់ភ័ស្តុតាងណាមួយច្រានចោលការរកឃើញអំពីរចនាសម្ព័ន្ធគ្រប់គ្រងអំណាចជាធរមាន នៅពេលដែលពាក់ព័ន្ធនោះទេ ឬឬគោលនយោបាយដាក់គោលដៅលើអតីតទាហាន និងមន្ត្រី លន់ នល់។ គាត់

[51] **F2/7** សំណើទីប្រាំសុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ៥៧។

[52] **E319/13.3.17** កំណត់ហេតុនៃការស្តាប់ចម្លើយ [សាក្សីលេខ២] ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៣។

[53] **F2/7** សំណើទីប្រាំសុំឲ្យទទួលយកភ័ស្តុតាងបន្ថែម ត្រង់កថាខណ្ឌ២៣។

លើកឡើងតែព្រឹត្តិការណ៍ "ចាប់ផ្តើមពីចុងឆ្នាំ១៩៧៦"[54] ពាក់កណ្តាលឆ្នាំ១៩៧៧[55] និងក្នុងឆ្នាំ១៩៧៨[56] ដែលជាពេលវេលាយូរក្រោយព្រឹត្តិការណ៍ក្នុងសំណុំរឿងលេខ០០២/០១ នៅទួលពោធិ៍ជ្រៃ។

33. នួន ជា មិនមានបំណងបង្ហាញថាតើ ផ្នែកជាក់លាក់នៃព័ត៌មានដែលគាត់ដកស្រង់ និងសង្ខេបទាក់ទងនឹងឯកសារនេះ អាចជាកត្តាកំណត់ក្នុងសាលក្រមដោយរបៀបណានោះទេ។ ក្នុងការបញ្ជាក់ទូទៅជាងនេះ គាត់ធ្វើការអះអាងស្រដៀងគ្នានេះចំពោះតម្លៃនៃភស្តុតាងរបស់សាក្សីលេខ២ ពីព្រោះពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីលេខ១ *គឺថា* "ស៊ីសង្វាក់គ្នាយ៉ាងជាក់លាក់ជាមួយនឹងការរៀបរាប់របស់សាក្សី 2" និង "អាចជួយលាតត្រដាងនូវហេតុការណ៍ពិតបិទបាំងនៅក្នុងភូមិភាគពាយ័ព្យរហូតមកដល់ពេលនេះ"។ ការអះអាងទាំងអស់នោះមិនពិតនោះទេ។ ជាងនេះទៅទៀត ក្រោយពីបានស្តាប់សក្ខីកម្មរបស់សាក្សី SCW-5 រួចមក វាច្បាស់ណាស់ថាវាមិនមែនជាកត្តាកំណត់នៅក្នុងសាលក្រមនោះទេ។ SCW-5 បានជំទាស់ទៅនឹងការអះអាងរបស់ នួន ជា ទៅវិញទេ ដែលថាបក្សស្ថិតនៅក្នុងសង្គ្រាមផ្ទៃក្នុងនៅឆ្នាំ១៩៧៥ ហើយថែមទាំងបានផ្តល់ភស្តុតាងបន្ថែមបញ្ជាក់ថា ទួលពោធិ៍ជ្រៃគឺជាផ្នែកមួយនៃគោលនយោបាយរបស់ថ្នាក់លើ ប.ក.ក ក្នុងការកម្ទេចមន្ត្រីរដ្ឋការ លន់ នល់។

34. នួន ជា យោងជាក់លាក់ទៅលើតែផ្នែកមួយនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ២ តែប៉ុណ្ណោះនៅពេលដែលព្យាយាមបញ្ជាក់ពីភាពពាក់ព័ន្ធរបស់វា ដោយលើកឡើងថា សាក្សីលេខ២ "ពន្យល់ថា ផែនការរបស់កងពលយោធាពីរនៅភូមិភាគពាយ័ព្យដើម្បី 'វាយបកប្រឆាំងនឹង ប៉ុល ពត ត្រូវបានលេចឮ 'តាមរយៈគិញមួយចំនួនរបស់មជ្ឈិម' ហើយកម្មាភិបាលភូមិភាគពាយ័ព្យ [SCW-5] ត្រូវបានចាប់ខ្លួនដោយសារគាត់ត្រូវបានគេចោទថាបានដឹកសម្ភារៈយោធា ទៅភ្នំវាយចាប"[57]។ នៅពេល មេធាវីការពារក្តី នួន ជា បានអានផ្នែកនៃកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីលេខ២ នេះទៅកាន់ SCW-5 ក្នុងពេលផ្តល់សក្ខីកម្មរបស់ SCW-5 ហើយគាត់បានបដិសេធចម្លើយនេះ។ មេធាវីការពារក្តី នួន ជា បានសុំឱ្យ SCW-5 បញ្ជាក់ពីការពិតថា ១) គាត់ត្រូវបានចាប់ខ្លួន និង ២) គាត់ត្រូវបានចោទថាបានដឹកសម្ភារៈយោធា។ SCW-5 បានឆ្លើយថា៖

---

[54] F2/7 សំណើទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ២៧។

[55] F2/7 សំណើទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ២៧។

[56] F2/7 សំណើទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ២៥។

[57] F2/7 សំណើទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម ត្រង់កថាខណ្ឌ៥៦។

បាទ គឺគេចាប់ខ្លួនខ្ញុំអត់បានទេ។ ហើយអាវុធដែលយកទៅទុកហ្នឹង គឺនិយាយដូចជា ច្រំដែលថា មិនបានយកទៅលាក់ទុកដើម្បីប្រឆាំងនឹង ប៉ុល ពត ទេ គឺរក្សាទុកឲ្យបានល្អ តែត្រង់ ប៉ុល ពត ចាប់ខ្ញុំ វាចាប់ខ្ញុំ ចាប់មិនបាន គឺខ្ញុំក៏សម្រេចចិត្តយកអាវុធហ្នឹងវិញទៅ វ៉ៃបកវិញទៅបាទ[58]។

## *គ. សំណើសុំកំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ៣*

35. នួន ជា បានស្វែងរកឲ្យបានទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី[59] ពីសាក្សីលេខ៣[60]។ សហព្រះរាជអាជ្ញាសូមជំទាស់ទៅនឹងសំណើនេះ។

36. ភស្តុតាងដែលបានផ្តល់ដោយសាក្សីលេខ៣ មិនមែនជាកត្តាកំណត់នៅក្នុងសាលក្រមទេ ហើយមិនមានសារៈប្រយោជន៍ក្នុងការសម្តែងឲ្យឃើញការពិតទេ។ គាត់មិនពិភាក្សាពីទួលពោធិ៍ជ្រៃទេ និងមិនបានផ្តល់ភស្តុតាងណាមួយ ដែលទាត់ចោលនូវការរកឃើញអំពីរចនាសម្ព័ន្ធសិទ្ធិអំណាចតាមឋានានុក្រមមានប្រសិទ្ធិភាពមួយ នាសម័យកាលពាក់ព័ន្ធនោះឡើយ ឬឬគោលនយោបាយដាក់គោដៅលើអតីតទាហាន និងមន្ត្រី លន់ នល់ ។ គាត់ត្រូវបានបញ្ជាក់នូវព្រឹត្តិការណ៍នានាដែលចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ១៩៧៧ ឬនៅចុងឆ្នាំ១៩៧៧[61] គឺយូរជាងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃដែលបានលើកឡើងនៅក្នុងសាលក្រម។

37. នួន ជា មិនបានប៉ុនប៉ងបង្ហាញថាតើផ្នែកជាក់លាក់នៃព័ត៌មានដែលគាត់ដកស្រង់ និងសង្ខេប ដែលទាក់ទងនឹងឯកសារនេះ អាចបានទៅជាកត្តាកំណត់នៅក្នុងសាលក្រមដោយរបៀបណានោះទេ។ នៅក្នុងយុត្តិកម្មទូទៅជាងនេះ គាត់បានធ្វើការអះអាងស្រដៀងគ្នាពាក់ព័ន្ធនឹងគុណតម្លៃនៃភស្តុតាងរបស់សាក្សីលេខ៣ ដូចដែលគាត់បានធ្វើពាក់ព័ន្ធនឹងភស្តុតាងរបស់សាក្សីលេខ១ គឺថា "ស៊ីសង្វាក់

---

[58] សេចក្តីព្រៀងប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ត្រង់ 11.39.53។

[59] **E319/13.3.58** កំណត់ហេតុស្តាប់ចម្លើយ [សាក្សីលេខ៣], ៣ កញ្ញា ២០១៣។

[60] **F2/7** សំណើលើកទីប្រាំសុំឲ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កថាខណ្ឌ ៣១-៣៦។

[61] **F2/7** សំណើលើកទីប្រាំសុំឲ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កថាខណ្ឌ ៣៣។ **E319/13.3.58** កំណត់ហេតុស្តាប់ចម្លើយ [សាក្សីលេខ៣], ៣ កញ្ញា ២០១៣, ត្រង់ឆ.2 ("ពួកនិរតីចូលមកដល់បាត់ដំបងនេះប្រហែលជាពាក់កណ្តាល ឬក៏ចុងឆ្នាំ ១៩៧៧")។

គ្នាយ៉ាងជាក់លាក់ជាមួយនឹងការរៀបរាប់របស់សាក្សី SCW-5" និង "លាតត្រដាងនូវហេតុការណ៍បិទបាំងនៅក្នុងភូមិភាគពាយ័ព្យ"។ ដូចដែលបានថ្លែងនៅខាងលើស្រាប់ ការអះអាងទាំងនោះ គឺមិនពិត និង/ឬ មិនពាក់ព័ន្ធទេ។

38. នួន ជា បានយោងយ៉ាងជាក់លាក់ទៅរកតែផ្នែកមួយប៉ុណ្ណោះនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ៣ នៅក្នុងការប៉ុនប៉ងធ្វើយុត្តិកម្មលើភាពពាក់ព័ន្ធរបស់វា ដោយបានថ្លែងថា សាក្សីលេខ៣ "បានរៀបរាប់បន្ថែមអំពីក្រុមទាំងនេះ ដោយបានពន្យល់ថា [ភូមិភាគពាយ័ព្យដែលនៅក្រោម] រស់ ញឹម ត្រូវបានចោទថាជាប់និន្នាការ "ជាមួយខ្មែរវៀតមិញ"..."[62]។ មេធាវីការពារក្តី នួន ជា បានអានត្រង់វគ្គនេះឱ្យសាក្សី SCW-5 ស្តាប់ នៅពេលដែលគាត់បានចូលបង្ហាញខ្លួន ដើម្បីផ្តល់សក្ខីកម្ម។ នៅក្នុងចម្លើយតបជាដំបូង សាក្សី SCW-5 បានរៀបរាប់ពីបទពិសោធន៍របស់គាត់ ផ្ទាល់ ដោយមានការលើកចោទប្រកាន់ខុសអំពីទំនាក់ទំនងជាមួយវៀតណាម៖ "...ប៉ុណ្ណឹង ហើយថាខ្ញុំក្បត់ ហើយខ្ញុំដែលក្បត់ស្អី ហើយខ្ញុំដែលទៅធ្វើខ្ញុំយួន ខ្មែរយះយួនឯណា..."[63]។ បន្ទាប់ មក មេធាវីការពារក្តី នួន ជា បានបន្តទៀតដោយការសួរយ៉ាងជាក់លាក់អំពី រស់ ញឹម និងអ្នកដទៃទៀតដែល នួន ជា បានលើកចោទប្រកាន់ថាជាផ្នែកនៃក្រុមបះបោរដែលបានគ្រោងរៀបចំ។

> [មេធាវីការពារក្តី នួន ជា]៖ បាទ សោ ភឹម ឬក៏ រស់ ញឹម ឪពុកធម៌របស់លោក ឬក៏ ចក្រី ឬក៏ កុយ ធួន ឬក៏ ទីវ អុល ហ្នឹងមានទំនាក់ទំនងអ្វី មានទំនាក់ទំនងណាមួយជាមួយ វៀតណាមសម្រាប់ការបះបោរនេះដែរឬទេ?
> [សាក្សី SCW-5]៖បាទ អត់ដឹងទេ[64]។

## *ឃ. សំណើសុំកំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ៤*

39. នួន ជា បានស្វែងរកឱ្យបានទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី[65] ពីសាក្សីលេខ៤[66]។ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងសំណើនេះ។

[62] **F2/7** សំណើលើកទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កថាខណ្ឌ ៥៥។

[63] សេចក្តីព្រាងប្រតិចារឹក, ៦ កក្កដា ២០១៥, ត្រង់ 11.28.46។

[64] សេចក្តីព្រាងប្រតិចារឹក, ៦ កក្កដា ២០១៥, ត្រង់ 11.30.47។

[65] **E319/19.3.198** កំណត់ហេតុស្តាប់ចម្លើយ [សាក្សីលេខ៤], ១៥ តុលា ២០១៤។

[66] **F2/7** សំណើលើកទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កថាខណ្ឌ ៣៧-៤១។

40. ភស្តុតាងដែលបានផ្តល់ដោយសាក្សីលេខ៤ មិនមែនជាកត្តាកំណត់នៅក្នុងសាលក្រមទេ ហើយមិនមានសារៈប្រយោជន៍ក្នុងការសម្តែងឱ្យឃើញការពិតទេ។ គាត់មិនពិភាក្សាពីទួលពោធិ៍ជ្រៃទេ និងមិនបានផ្តល់ភស្តុតាងណាមួយ ដែលទាត់ចោលនូវការរកឃើញអំពីរចនាសម្ព័ន្ធសិទ្ធិអំណាចតាមឋានានុក្រមមានប្រសិទ្ធិភាពមួយ នាសម័យកាលពាក់ព័ន្ធនោះឡើយ ឬឬឬគោលនយោបាយដាក់គោលដៅលើអតីតទាហាន និងមន្ត្រី លន់ នល់។ គាត់ត្រូវបានបញ្ជាក់នូវ ព្រឹត្តិការណ៍នានាដែលចាប់ផ្តើមនៅ "ចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨" និងជាបន្តបន្ទាប់មកទៀត[67] គឺយូរជាងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ទាក់ទងនឹងសាលក្រមលើសំណុំរឿង០០២/០១។

41. នួន ជា មិនបានប៉ុនប៉ងបង្ហាញថាតើផ្នែកជាក់លាក់នៃព័ត៌មានដែលគាត់ដកស្រង់ និងសង្ខេប ដែលទាក់ទងនឹងឯកសារនេះ អាចបានទៅជាកត្តាកំណត់នៅក្នុងសាលក្រមដោយរបៀបណានោះទេ[68]។ នៅក្នុងយុត្តិកម្មទូទៅជាងនេះ គាត់<u>មិនបាន</u>ធ្វើការបញ្ជាក់ជាក់លាក់ដល់ភស្តុតាងរបស់សាក្សីលេខ៤ទេ ហើយគ្រាន់តែលើកឡើងដោយការយោងដល់ "គ្រប់សាក្សីទាំងបួននាក់ ក្នុងសំណុំរឿង០០៤" ប៉ុណ្ណោះ ចំពោះចំណុចទូទៅដែលបានលើកឡើង និងទាត់ចោលនៅខាងលើគឺមិនពិត និង/ឬ មិនពាក់ព័ន្ធទេ។

42. យ៉ាងណាក៏ដោយ វាមិនមានអ្វីទាល់តែសោះដែលថាភស្តុតាងពីក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ៤ ត្រូវបានដាក់ឱ្យសាក្សី SCW-5 នៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់គាត់។ នៅក្នុងសំណើរបស់គាត់ នួន ជា បានស្រង់អត្ថបទមួយវគ្គពីក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ៤ពាក់ព័ន្ធនឹងការលើកឡើងពីការចាប់ខ្លួន រស់ ញឹម ក្នុងឆ្នាំ១៩៧៨ ទាក់ទងនឹងឧទ្ធម្ភាចក្រមួយគ្រឿងថាជាការ "រៀបរាប់អំពីកាលៈទេសៈ ដែលបង្ហាញឱ្យឃើញពីការផ្លាស់ប្តូរថ្នាក់ដឹកនាំភូមិភាគ ពាយ័ព្យ"[69]។ មេធាវីការពារក្តី នួន ជា បានយកព័ត៌មានពាក់ព័ន្ធនឹងសាក្សី៤ កំពុងស្វែងរកឧទ្ធម្ភាចក្រ និងត្រូវបានគេប្រាប់ថា រស់ ញឹម ត្រូវបានគេចាប់ខ្លួនហើយ ដោយបានបញ្ចេញបញ្ចូលជាមួយនឹងព័ត៌មានដែលបានមកពីកំណត់ហេតុ ស្តាប់ចម្លើយសាក្សីលេខ១ ទាក់ទងនឹង រស់ ញឹម រត់គេចខ្លួនទៅស៊ីសូផុន ដោយបានដាក់បង្ហាញ ថាជាភស្តុតាងដែលបានផ្តល់ដោយសាក្សីតែម្នាក់ (មិនបានផ្តល់ការដកស្រង់ជូនអង្គជំនុំជម្រះ ឬភាគីទេ) និងបានស្វែងរកប្រតិកម្មរបស់សាក្សី SCW-5៖

[67] F2/7 សំណើលើកទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម, គ្រង់កថាខណ្ឌ ៣៩, ៤១។

[68] F2/7 សំណើលើកទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម, គ្រង់កថាខណ្ឌ ៣៧-៤១។

[69] F2/7 សំណើលើកទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម, គ្រង់កថាខណ្ឌ ៣៩។

[មេធាវីការពារក្តី នួន ជា]៖ មានសាក្សីម្នាក់ដែលបានឆ្លើយប្រាប់មន្ត្រីស៊ើបអង្កេតថា ឪពុកធម៌របស់លោកបានដឹងអំពីការ -- ផែនការចាប់ខ្លួន ក៏បានរត់គេចចេញទៅស៊ីសូផុន ហើយត្រូវចាប់បាននៅស្វាយស៊ីសូផុន ដោយសារតែគេយកឧទ្ធម្ភាចក្រមួយជិះទៅចាប់ខ្លួនគាត់ តើត្រឹមត្រូវដែរឬទេ?

[សាក្សី SCW-5]៖ បាទ ខ្ញុំអត់ដឹងទេ ប៉ុន្តែកាលនោះអត់មានឧទ្ធម្ភាចក្រទេ វាអស់ហើយ យន្តហោះក៏អត់មានដែរ...[70]។

### ង. *សាក្សីបីនាក់ដែលមានឈ្មោះនៅក្នុងសៀវភៅ* នៅពីក្រោយវាលពិឃាត

43. នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការកោះហៅបុគ្គលចំនួនបីនាក់ដែលបានរៀបរាប់នៅក្នុងសៀវភៅ *នៅពីក្រោយវាលពិឃាត* ដើម្បីឱ្យមកធ្វើជាសាក្សី[71]។ សហព្រះរាជអាជ្ញាជំទាស់ ទៅនឹងសំណើនេះ។

44. ភស្តុតាងរបស់គាត់មិនត្រឹមតែ មិនមានសារៈប្រយោជន៍ក្នុងការសម្តែងឱ្យឃើញការពិត និងមិនមែនជាកត្តាកំណត់នៅក្នុងសាលក្រមប៉ុណ្ណោះទេ ក៏ប៉ុន្តែសំណើទាំងនេះថែមទាំងមិនបានបង្ហាញជាភស្តុតាងអំពីការព្យាយាមហួតចត់ថែមទៀតផង ដែលថាអង្គជំនុំជម្រះនេះបានយល់ឃើញថា ជាការ "សំខាន់ណាស់ ដើម្បីជៀសវាងកុំឱ្យមានការប្រើប្រាស់យុត្តិសាស្ត្រនៃការតវ៉ាដែលពុំមានប្រសិទ្ធិភាព និងជាការរំខាន"[72]។

45. សំណើរបស់ នួន ជា សុំឱ្យកោះហៅបុគ្គលទាំងនេះឱ្យមកធ្វើជាសាក្សី គឺជាបុព្វវាចាទាំងស្រុង អំពីព័ត៌មាននៅក្នុងសៀវភៅ *នៅពីក្រោយវាលពិឃាត* ។ សៀវភៅនោះធ្លាប់មាននៅក្នុងសំណុំរឿង តាំងពីមានការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីលើភស្តុតាងក្នុងសំណុំរឿង០០២/០១មកម្ល៉េះ[73]។ ដូច

---

[70] សេចក្តីព្រាងប្រតិចារឹក, ៦ កក្កដា ២០១៥, ត្រង់ 11.44.05។

[71] **F2/7** សំណើលើកទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កថាខណ្ឌ ៤៣-៤៦។

[72] **F2/5** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, ២៩ ឧសភា ២០១៥, ត្រង់កថាខណ្ឌ ១៦។

[73] **E152.2**, នៅពីក្រោយវាលពិឃាត (ភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងឯកសារ **E152**, ការបង្ហាញជូនរបស់សហព្រះរាជអាជ្ញា អំពីការធ្វើសម្ភាសន៍ជាមួយ ខៀវ សំផន និងសៀវភៅដែលមានចំណងជើងថា "នៅពីក្រោយវាលពិឃាត៖ មេដឹកនាំខ្មែរក្រហមម្នាក់

ដែល នួន ជា បានទទួលសារភាព៖ "នេះគឺជាសៀវភៅដែលបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០១០ ត្រូវបានចែកចាយយ៉ាងទូលំទូលាយត្រូវបានគេស្គាល់ មាននៅក្នុងសំណុំរឿង ហើយបច្ចុប្បន្នមានលក់នៅបណ្ណាគារម៉ូញ៉ូម៉ែនក្នុងប្រទេសកម្ពុជាទៀតផង"[74]។ យ៉ាងណាក៏ដោយ នួន ជា មិនបានស្វែងរកធ្វើការកោះហៅសាក្សីទាំងនេះទេ នៅក្នុងអំឡុងពេលសវនាការនៃសំណុំរឿង០០២/០១។

46. ទាក់ទងទៅនឹងសាក្សី 2-TCW-960[75] នួន ជា ក៏បានពឹងផ្អែកផងដែរទៅលើឯកសារផ្សេងៗ ពីរទៀត[76] គឺ E3/1894 និង E3/3849 ដើម្បីគាំទ្រសំណើរបស់គាត់ឲ្យកោះហៅសាក្សីនេះ។ ទីមួយ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ឯកសារទាំងពីរនេះក៏សុទ្ធតែមាននៅក្នុងសំណុំរឿង០០២/០១ រួចស្រាប់ហើយ តែ នួន ជា មិនទាន់បានស្វែងរកកោះហៅសាក្សីនេះឡើយ។ ទីពីរ សហ ព្រះរាជអាជ្ញាកត់សម្គាល់ថា ឯកសារទាំងពីរនេះគឺសុទ្ធតែជាចម្លើយសារភាពនៅស-២១ ដែលនៅ ក្នុងការអះអាងរបស់ នួន ជា ដែលថាឯកសារទាំងនោះគឺជាការបញ្ជាក់បន្ថែមលើព័ត៌មានដែលបាន បន្ថែមផ្តល់ដោយសាក្សី 2-TCW-960 ជូនទៅ Gina Chon និង ថេត សម្បត្តិ (រួមទាំងសម្រង់ នានានៅក្នុងកំណត់សម្គាល់ជើងទំព័រផង[77]) គឺកំពុងត្រូវបានប្រើប្រាស់យ៉ាងច្បាស់លាស់ សម្រាប់ ការពិតនៃបញ្ហានានាដែលបានអះអាង។ ដូចដែលសហព្រះរាជអាជ្ញាធ្លាប់បានកត់សម្គាល់ពីមុន ដូច្នោះដែរ គឺថា "ច្បាប់ជាតិ និងច្បាប់អន្តរជាតិ រារាំងដោយច្បាស់លាស់ដល់ភាគីមិនឲ្យប្រើប្រាស់ ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ដើម្បីបង្ហាញសក្ខីកម្មពីការពិតនៃរឿងរ៉ាវនានាដែលបាន "ឆ្លើយសារភាព""[78]។ បន្ថែមលើនេះ "តាមរយៈអង្គហេតុជាក់លាក់ទាំងឡាយនៃសំណុំរឿងនេះ ការហាមឃាត់នេះអាចអនុវត្តយ៉ាងច្បាស់សាស់ក្នុងការរារាំង នួន ជា ដែលភស្តុតាងក្នុងសំណុំរឿង ០០២/០២ នឹងបង្ហាញថាគាត់បានគ្រប់គ្រងនៅគុក ស-២១ ដែលជាកន្លែងអ្នកទោសត្រូវបានធ្វើ

និងជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះជាច្រើនរបស់គាត់", ដោយលោក GINA Chon និងលោក ថេត សម្បត្តិ, ៥ ធ្នូ ២០១១)។ *សូមអានផងដែរ* **E3/4202** នៅពីក្រោយវាលពិឃាត។

[74] **F2/7** សំណើលើកទីប្រាំសុំឲ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កថាខណ្ឌ ៦៤។

[75] នួន ជា យោងកថាខណ្ឌនោះ និងទៅកំណត់សម្គាល់ជើងទំព័រពាក់ព័ន្ធទៅនឹងឯកសារទាំងនេះ "ដែលយោងទៅបុគ្គលម្នាក់ហាក់ដូចជា 2-TCW-961" (F2/7 ត្រង់កថាខណ្ឌ ៤៥)។ យ៉ាងណាក៏ដោយ ការយោងទៅឯកសារទាំងនោះ ក៏ដូចជាទីកន្លែងនៃកថាខណ្ឌក្នុងផ្នែកនេះដែលបានលើកឡើងពីសាក្សី 2-TCW-960 ដែរ គឺជាការច្បាស់ណាស់ដែលថាគាត់បានយោងទៅសាក្សី 2-TCW-960។

[76] **F2/7** សំណើលើកទីប្រាំសុំឲ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កថាខណ្ឌ ៤៥។

[77] **F2/7** សំណើលើកទីប្រាំសុំឲ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កំណត់សម្គាល់ជើងទំព័រលេខ ៦៨។

[78] **F26/7** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបញ្ជីឯកសារសាក្សី សម្រាប់សាក្សី SCW-3, SCW-4 និង SCW-5, ២៩ មិថុនា ២០១៥, ត្រង់កថាខណ្ឌ ៥។

ទារុណកម្មជាប្រចាំ និងគួរឱ្យភ័យខ្លាច មិនឱ្យប្រើប្រាស់ចម្លើយសារភាពដើម្បីបង្ហាញថារឿងរ៉ាវដែល "បានសារភាព" ជាការពិតឡើយ។ ពីព្រោះការណ៍នេះអាចលើកពីគោលបំណងដែលថា អំពើទារុណកម្មជាការធ្វើឱ្យឈឺចាប់ ដើម្បីធ្វើយុត្តិកម្មលើឧក្រិដ្ឋកម្មទាំងឡាយរបស់របបនោះ"[79]។

47. ចម្លើយសារភាពមួយក្នុងចម្លើយសារភាពនៅស-២១ទាំងពីរនេះ ត្រូវបានពឹងផ្អែកដោយ នួន ជា យ៉ាងជាក់ច្បាស់ បានបំប៉ោងពីភាពសមស្របដែលនៅពីក្រោយការហាមឃាត់នេះពីមុន។ ឯកសារ E3/1894 គឺជា "ចម្លើយសារភាព" នៅស-២១ របស់ សៀង ប៉ូយ ហៅ ស៊ាន គឺជាកម្មាភិបាលមកពីភូមិភាគពាយព្យ៍ដែលត្រូវបានចោទថាបានចូលជាខ្មែ CIA ។ អ្នកសួរចម្លើយ គាត់នៅស-២១ បានធ្វើការកត់ចំណាំសម្រាប់ថ្នាក់លើរបស់គាត់ថា៖ "ខ្ញុំសង្កេតទៅ វាមិនសារភាព ... ពេលចាប់ធ្វើទារុណកម្ម វាក៏សុខចិត្តសារភាព ទាំងពីកាទាក់ទង + សកម្មភាព + ផែនការជាខ្សែសង្វាក់រហូត អ/ក (ចាប់ខ្លួន)"[80]។ ដូច្នេះ គឺគាត់បានផ្តល់នូវ "ផែនការក្បត់" របស់គាត់ រួមមានព័ត៌មានដែលបានដកស្រង់ដោយ នួន ជា នៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៦៨ នៃសំណើសុំបន្ថែមភស្តុតាងទីប្រាំ។ នៅពេលដែលចម្លើយសារភាពត្រូវបានបញ្ចប់ មានចំណាររមួយនៅលើទំព័រទីមួយដែលគេបន្ទាប់មកបញ្ជូនទៅ "ជូនបងនួន 2ច្បាប់"[81]។ ហើយពេលនេះ បងនួន បានប្រើប្រាស់ជាមួយនឹងអង្គជំនុំជម្រះនេះ សម្រាប់ការពិតនៃបញ្ហាដែលបានអះអាងនៅទីនេះ។

48. លើសពីនេះ នួន ជា មិនបានធ្វើការបង្ហាញជាក់លាក់ណាមួយទេថា ព័ត៌មានដោយសាក្សីទាំងនេះនឹងបានជាកត្តាកំណត់មួយនៅក្នុងសាលក្រម ឬមានសារៈប្រយោជន៍ក្នុងការសម្តែងឱ្យឃើញ ការពិត។ ជាដំបូង វាត្រូវបានគេកត់សម្គាល់ថា ព័ត៌មានដែល នួន ជា បានស្វែងរកធ្វើការពឹងផ្អែក នៅទីនេះក្នុងគោលបំណងដើម្បីគាំទ្រដល់សំណើរបស់គាត់ដើម្បីឱ្យបានកោះហៅសាក្សីទាំងនេះ គឺ មិនមែនបានមកពីកំណត់ហេតុស្តាប់ចម្លើយសាក្សីនានា ដែលបានស្តាប់ដោយចៅក្រមស៊ើបអង្កេតណាមួយនោះទេ ក៏ប៉ុន្តែគឺបានមកពីសៀវភៅមួយក្បាលដែលបានសរសេរដោយបុគ្គលពីរូបដែលមិនធ្លាប់បានផ្តល់សក្ខីកម្មនៅចំពោះមុខ អវតក នោះឡើយ។

---

[79] **F26/7** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបញ្ជីឯកសារសាក្សី សម្រាប់សាក្សី SCW-3, SCW-4 និង SCW-5, ២៩ មិថុនា ២០១៥, ត្រង់កថាខណ្ឌ៥។

[80] **E3/1894** S-21 ចម្លើយសារភាពរបស់ សៀង ប៉ូយ ហៅ ស៊ាន, ៩ វិច្ឆិកា ១៩៧៧, ត្រង់ ENG 00702085។

[81] **E3/1894** S-21 ចម្លើយសារភាពរបស់ សៀង ប៉ូយ ហៅ ស៊ាន, ៩ វិច្ឆិកា ១៩៧៧, ត្រង់ ENG 00702082។ *សូម អានផងដែរ* **E3/1579** កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ២១-១០-២០០៩, ត្រង់ ENG ERN 00398207 (ឌុច បានកំណត់អត្តសញ្ញាណថា ចំណារទាំងនេះ គឺសរសេរដោយ សុន សេន)។

49. លើសពីនេះ មិនមានបុគ្គលណាម្នាក់ក្នុងចំណោមពួកគាត់ពិភាក្សាពីទួលពោធិ៍ជ្រៃទេ ហើយក៏មិនបានផ្តល់ភស្តុតាងណាមួយ ដែលទាត់ចោលនូវការរកឃើញអំពីរចនាសម្ព័ន្ធសិទ្ធិអំណាចតាមឋានានុក្រមមានប្រសិទ្ធិភាពមួយ នាសម័យកាលពាក់ព័ន្ធនោះឡើយ ឬឬគោលនយោបាយដាក់គោលដៅលើអតីតទាហាន និងមន្ត្រី លន់ នល់។ កាលបរិច្ឆេទមុនគេបំផុត ដែលបានពោលឡើងដោយនរណាក៏ដោយក្នុងចំណោមពួកគាត់គឺឆ្នាំ១៩៧៦[82] នៅក្រោយបន្ទាប់ពី ព្រឹត្តិការណ៍នានានៅទួលពោធិ៍ជ្រៃ ដែលចំពោះព្រឹត្តិការណ៍នោះ នួន ជា ត្រូវបានផ្តន្ទាទោស នៅក្នុងសំណុំរឿង០០២/០១។

50. នួន ជា បានយោងដល់សេចក្តីថ្លែងអះអាងរបស់បុគ្គលទាំងនេះ ដោយបាននិយាយថាពួកគាត់ "បាននិយាយអំពីគំនរលាក់ទុក ... ដើម្បីត្រៀមវាយប្រហារ" និង "ផែនការនានារួមទាំងការបំផ្ទុះស្ពាន" ដែល "បានផ្តល់ទម្ងន់បន្ថែមលើការរៀបរាប់របស់សាក្សី SCW-5"[83]។ ក៏ប៉ុន្តែ សាក្សី SCW-5 បានផ្តល់សក្ខីកម្មថាមិនមានផែនការប៉ះបោរ, ហើយជាក់ច្បាស់ណាស់ មិនមែនជាផែនការមួយដែលរួមបញ្ចូល រស់ ញឹម នោះទេ ឬក៏សម្រាប់បញ្ហានោះដែរ, វន វ៉េត និង សោ ភឹម ដូចវគ្គអត្ថបទដែលបានកំណត់ដល់ការអះអាងរបស់សាក្សី 2-TCW-959 នោះទេ[84]។

51. វគ្គអត្ថបទដែលបានកំណត់ចំពោះសាក្សី 2-TCW-959 អះអាងថាការត្រៀមរៀបចំនានាសម្រាប់ផែនការក្បត់មួយ "ដើម្បីផ្តួលរំលំ ប៉ុល ពត" ត្រូវបានក្លែងបន្លំដោយការនិយាយថាពួកគាត់ "ត្រៀមធ្វើសង្គ្រាមជាមួយថៃ"[85]។ យ៉ាងណាក៏ដោយ សាក្សី SCW-5 ត្រូវបានតាំងសំណួរអំពីលទ្ធភាពនេះ ហើយក៏បានប្រកែកអំពីការដឹងឮរឿងរ៉ាវនេះ។

> [មេធាវីការពារក្តី នួន ជា]៖ ...តើលោកដឹងអំពីផែនការ គឺមានផែនការដើម្បីធ្វើឃាត ប៉ុល ពត ក៏ដូចជាធ្វើវិទ្ធង្សនាបដិវត្តដោយការបង្កជាភាពវឹកវរទាំងផ្ទៃក្នុង និងខាងក្រៅ។ ឧទាហរណ៍ដូចជា ការធ្វើការវាយប្រយុទ្ធជាមួយប្រទេសថៃ ហើយក៏ដូចជាការរៀបចំធ្វើ

[82] **F2/7** សំណើលើកទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កថាខណ្ឌ ៥៦។

[83] **F2/7** សំណើលើកទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កថាខណ្ឌ ៥៦។

[84] *ចូរប្រៀបធៀប* F2/7 សំណើលើកទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កថាខណ្ឌ ៤៣ *ជាមួយនឹង* សេចក្តីព្រាង ប្រតិចារឹក, ៦ កក្កដា ២០១៥, ត្រង់ 11.01.05។

[85] **F2/7** សំណើលើកទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កថាខណ្ឌ ៤៣។

រដ្ឋប្រហារ។ តើលោកដឹងអំពីផែនការទាំងអស់នេះដែរទេ? តើលោកដឹងថាវាមានសកម្មភាពទាំងអស់នេះកើតឡើងដែរឬទេ នៅឆមាសទី២ ឆ្នាំ៧៥?

[សាក្សី SCW-5]៖ បាទ ខ្ញុំអត់ដឹងទេ បាទ។

### *ច. កំណត់ហេតុស្តាប់ចម្លើយលើកទីពីររបស់សាក្សី SCW-5 និងឧបសម្ព័ន្ធ*

52. នួន ជា បានស្វែងរកឱ្យបានទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយលើកទីពីររបស់សាក្សី SCW-5 និងឧបសម្ព័ន្ធរបស់វា[86]។ ដោយសារសាក្សី SCW-5 ធ្លាប់បានផ្តល់សក្ខីកម្មនៅក្នុងបណ្តឹងសាទុក្ខរួចហើយ សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយលើកទីពីរ និងឧបសម្ព័ន្ធពាក់ព័ន្ធ ថាជាភស្តុតាងថ្មីនៅក្នុងនៅក្នុងបណ្តឹងសាទុក្ខនេះទេ។

## IV. សេចក្តីសន្និដ្ឋាន

53. ចំពោះហេតុផលនានាដែលបានរៀបរាប់ខាងលើនេះ សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល៖

១) បដិសេធលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីលេខ ១-៤។

២) បដិសេធលើសំណើសុំឱ្យស្តាប់សក្ខីកម្មសាក្សីលេខ1, 2, 2-TCW-959, 2-TCW-960, និង 2-TCW-961 និង

៣) យល់ព្រមតាមសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយបន្ថែមរបស់សាក្សី SCW-5 និងឧបសម្ព័ន្ធពាក់ព័ន្ធ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |

[86] **F2/7** សំណើលើកទីប្រាំសុំឱ្យទទួលយកភស្តុតាងបន្ថែម, ត្រង់កថាខណ្ឌ ៤៧-៤៨។ **E319.1.28** កំណត់ហេតុស្តាប់ចម្លើយសាក្សី SCW-5, ២៧ វិច្ឆិកា ២០១៣។ **E319.1.28.1** ឧបសម្ព័ន្ធភ្ជាប់ទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី [SCW-5], ២៧ វិច្ឆិកា ២០១៣។